រាជធានីភ្នំពេញ, ថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧

# សេចក្តីថ្លែងការណ៍

# ស្តីអំពី

# បើកទូលាយទីធ្លាសាធារណៈ និងលើកស្ទួយសិទ្ធិប្រមូលផ្តុំ និងហែក្បួន ក្នុងដំណើរការឃោសនាបោះឆ្នោតរបស់គណបក្សប្រកួតប្រជែង

សមាគម និងអង្គការសង្គមស៊ីវិលនៅកម្ពុជា នៃបន្ទប់ស្ថានការណ៍សម្រាប់ការបោះឆ្នោតឆ្នាំ២០១៧ យល់ឃើញថា មិនត្រឹមត្រូវ និងមិនសមហេតុផលចំពោះការជូនដំណឹងរបស់សាលារាជធានីភ្នំពេញ ស្តីពីការមិនអនុញ្ញាតឲ្យមានការហែក្បួនឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយឆ្លងកាត់លើកំណាត់ផ្លូវ និងតំបន់មួយចំនួននៅក្នុងរាជធានីភ្នំពេញ ក្នុងអំឡុងពេលឃោសនាបោះឆ្នោតចាប់ពីថ្ងៃទី២០ ខែឧសភា ដល់ ថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១៧។ កំណាត់ផ្លូវ និងតំបន់ជាច្រើនដែលសាលារាជធានីភ្នំពេញបានហាមឃាត់មិនឲ្យមានការក្បួនឃោសនាបោះឆ្នោតហែឆ្លង គឺជាតំបន់ទីប្រជុំជន និងប្រមូលផ្តុំដោយប្រជាពលរដ្ឋជាអ្នកបោះឆ្នោតក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់នៅថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៧។

ការហាមឃាត់ការហែក្បួនឃោសនាបោះឆ្នោតឆ្លងកាត់ទីប្រជុំជន ដែលប្រមូលផ្តុំដោយអ្នកបោះឆ្នោត ក្រោមហេតុផលបញ្ចៀសការកកស្ទះចរាចរ គឺមិនបង្ហាញអំពីការធានា និងការមានវិធានការរបស់រដ្ឋ (រដ្ឋាភិបាល និងអាជ្ញាធរ)ឲ្យមានការឃោសនាបោះឆ្នោតដោយសេរី និងត្រឹមត្រូវទេ។ ម្យ៉ាងទៀត ការឃោសនាបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់នីតិកាលទី៤នេះបានបន្ថយការហែក្បួនឃោសនាមកត្រឹមចំនួន០២ដង ហើយប្រសិនបើបន្ថយទីធ្លាសាធារណៈ និងផ្លូវសម្រាប់ធ្វើការឃោសនាទៀតនោះ ការអនុវត្តនៃសិទ្ធិប្រមូលផ្តុំ និងហែក្បួនធ្លាក់ចុះបន្ថែមទៀត។ យ៉ាងហោចណាស់ ការឃោសនាបោះឆ្នោតរបស់គណបក្សប្រកួតប្រជែងលើកនេះ គួរបើកទូលាយក្នុងការប្រើប្រាស់ទីធ្លាសាធារណៈផ្សេងៗ ដូចពហុកីឡាដ្ឋានជាតិ មហាវិទ្យាល័យ និងផ្លូវថ្នល់នានា ដូចការបោះឆ្នោតលើកមុន។

ក្នុងអំឡុងពេលបោះឆ្នោត និងការឃោសនាបោះឆ្នោត មានតែគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ត្រូវបានច្បាប់ផ្តល់សមត្ថកិច្ចដើម្បីរៀបចំ និងចាត់ចែងការប្រមូលផ្តុំ និងការហែក្បួនឃោសនាបោះឆ្នោត។ ការប្រមូលផ្តុំ និងការហែក្បួននេះមិនស្ថិតនៅក្នុងសមត្ថកិច្ចរបស់អាជ្ញាធរ ព្រោះមាត្រា០៣ នៃច្បាប់ការធ្វើបាតុកម្មដោយសន្តិវិធី មិនអនុវត្តចំពោះការប្រមូលផ្តុំ និងការហែក្បួនឃោសនាបោះឆ្នោតទេ។ អាជ្ញាធរ និងស្ថាប័នពាក់ព័ន្ធត្រូវចូលរួម និងផ្តល់កិច្ចសហប្រតិបត្តិការក្នុងការងាររៀបចំការបោះឆ្នោតនេះ បើយោងមាត្រា៨២ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់។

សមាគម និងអង្គការសង្គមស៊ីវិលនៅកម្ពុជា នៃបន្ទប់ស្ថានការណ៍សម្រាប់ការបោះឆ្នោតឆ្នាំ២០១៧ សូមស្នើដល់៖

1. គ.ជ.ប អនុវត្តសមត្ថកិច្ចក្នុងការចាត់វិធានការគ្រប់រូបភាព ដើម្បីធានាការបោះឆ្នោត ពិសេសការឃោសនាបោះឆ្នោតដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ឲ្យបានប្រសើរជាងដំណើរការឃោសនាបោះឆ្នោតលើកមុន និងដាក់ចេញវិធានការចាត់ចែងការងារដើម្បីការពារសន្តិសុខ ដូចមានចែងក្នុងមាត្រា ៤២ នៃច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តិទៅរបស់គ.ជ.ប។
2. អាជ្ញាធរសហការជាមួយ គ.ជ.ប ក្នុងការដាក់ពង្រាយកម្លាំងដើម្បីសម្របសម្រួល កុំឲ្យមានការកកស្ទះ និងសណ្តាប់ធ្នាប់ការហែក្បួនឃោសនារបស់គណបក្សនយោបាយទាំងនោះ ប្រកបដោយសន្តិវិធីនិងសុវត្ថិភាព។

**ព័ត៌មានបន្ថែមសូមទាក់ទង៖**

| | | | |
|---|---|---|---|
| 1. | លោក គល់ បញ្ញា | នាយកប្រតិបត្តិ COMFREL | ០១២ ៩៤ ២០ ១៧ |
| 2. | លោកស្រី ធីតា ឃឹះ | នាយិកាប្រតិបត្តិ SILAKA | ០១២ ៨៣ ៨៤ ៦៤ |
| 3. | លោក យង់ គិមអេង | នាយកប្រតិបត្តិ PDP-Center | ០១៦ ៨២ ៨២ ១១ |
| 4. | លោកស្រី រស់សុភាព | នាយិកាប្រតិបត្តិ GADC | ០១២ ៦២ ៧៨ ៥៧ |
| 5. | លោក ជាង សុខា | នាយកប្រតិបត្តិអង្គការ YRDP | ០១២ ៣៦ ០៤ ៦៤ |
| 6. | លោកស្រី ចក់ សុភាព | នាយិកាប្រតិបត្តិ CCHR | ០១១ ៩៤៣ ២១៣ |
| 7. | លោក តឹក វណ្ណារ៉ា | នាយិកាប្រតិបត្តិ NGO Forum | ០១២ ៧៩ ៣៤ ៨៩ |
| 8. | លោក មឿង តុលា | នាយកប្រតិបត្តិ Central | ០៩៣ ៥៥ ៦៦ ៤៣ |
| 9. | លោក ថាវ គឹមសាន | នាយកប្រតិបត្តិ LICADHO | ០១២ ៨០ ៧៧ ៦៣ |
| 10. | លោកស្រី ម៉ី សម្ផស្ស | អគ្គលេខាធិការ YCUD | ០៨១ ៣២ ៤៦ ៩១ |
| 11. | លោក ថេង សាវឿន | អគ្គលេខាធិការ CCFC | ០៧៨ ២២ ៥០ ៨៨ |
| 12. | លោក ស ម៉ូរ៉ា | ប្រធានសហព័ន្ធ CFSWF | ០១៦ ៥២ ៥៧ ៨១ |
| 13. | លោក សៀ ភារម្យ | នាយកប្រតិបត្តិ HRTF | ០១២ ៨៥ ២៣ ២៥ |
| 14. | លោក ឡុង ខែត | នាយកប្រតិបត្តិ FYP | ០១២ ៤០ ២៤ ០២ |
| 15. | លោក សៅ កុសល | នាយកប្រតិបត្តិ ស្តីទី STT | ០១៧ ៥៥ ៥៨ ៨៧ |
| 16. | លោក ប៉ែន សុមុនី | ប្រធាន CVS | ០១២ ៧០ ៨០ ៩៣ |
| 17. | លោក សឿង សារឿន | នាយកប្រតិបត្តិ CCC | ០១២ ៩០ ០៥ ០៣ |
| 18. | លោក ឡាយ សុវត្ថារ៉ា | អ្នកគ្រប់គ្រងកម្មវិធី CLEC | ០១២ ៨០ ៣៨ ២៧ |
| 19. | លោក ង៉ាច សាមីន | អ្នកសម្របសម្រួលគម្រោង CIYA | ០៩៩ ៩៤ ៨៤ ៧៧ |
| 20. | លោក វន់ ពៅ | ប្រធានសមាគម IDEA | ០៩៣ ៦២ ៩២ ៩៨ |